២០១៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខៈ ០៤៦ MIH / 2016

## ប្រកាស
## ស្តីពី
## ការកែសម្រួលការបែងចែកភារកិច្ច និងបន្ទុកទទួលខុសត្រូវ តាមវិស័យការងារ ជូនថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១ ៖** ត្រូវបានកែសម្រួលការបែងចែកភារកិច្ច និងបន្ទុកទទួលខុសត្រូវតាមវិស័យការងារ ជូនថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដូចខាងក្រោម ៖

១- ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ទទួលខុសត្រូវរួមរាល់កិច្ចការទូទៅរបស់ក្រសួង និងទទួលបន្ទុកដឹកនាំដោយផ្ទាល់លើការងារ ៖

- ចាត់តាំងមន្ត្រីរាជការ
- អគ្គាធិការដ្ឋាន
- នាយកដ្ឋានរដ្ឋបាល
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- សេវារដ្ឋបាលសាធារណៈនៅគ្រប់ច្រកចេញចូលតែមួយ
- និងបំពេញភារកិច្ចដទៃទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

២- ឯកឧត្តម **សាត សាមី** រដ្ឋលេខាធិការ, ជំនួយការរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំការងារ ៖

- នាយកដ្ឋានព័ត៌មាន
- នាយកដ្ឋានអភិវឌ្ឍន៍ស្តង់ដារ បណ្តុះបណ្តាល និងពិគ្រោះយោបល់
- នាយកដ្ឋានវិញ្ញាបនបត្រកម្ម
- នាយកដ្ឋានបញ្ញត្តកម្ម
- មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា
- និងបំពេញភារកិច្ចមួយចំនួនទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៣- ឯកឧត្តម **តោគ សុវណ្ណារិទ្ធ** រដ្ឋលេខាធិការ, ជំនួយការរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំការងារ ៖

- នាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- នាយកដ្ឋានវាយតម្លៃទទួលស្គាល់
- នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម
- មជ្ឈមណ្ឌលផលិតភាពជាតិ
- និងបំពេញភារកិច្ចមួយចំនួនទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៤- ឯកឧត្តម **ឯក សុនចាន់** រដ្ឋលេខាធិការ, ជំនួយការរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំការងារ ៖

- នាយកដ្ឋានទឹកស្អាត
- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- រដ្ឋាករទឹកស្វយ័តសៀមរាប
- និងបំពេញភារកិច្ចមួយចំនួនទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៥- ឯកឧត្តម **ហេង សុខគង់** រដ្ឋលេខាធិការ, ជំនួយការរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំការងារ ៖

- នាយកដ្ឋាននីតិកម្ម
- នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន
- នាយកដ្ឋានកិច្ចការឧស្សាហកម្ម
- និងបំពេញភារកិច្ចមួយចំនួនទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៦- លោកជំទាវ **ឡាយ ណាទីន** រដ្ឋលេខាធិការ, ជំនួយការរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំការងារ ៖

- នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ
- នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ
- នាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម
- នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ
- និងបំពេញភារកិច្ចមួយចំនួនទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៧- ឯកឧត្តម **គឹម ទូច** រដ្ឋលេខាធិការ, ជំនួយការរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំការងារ ៖

- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

- នាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម
- នាយកដ្ឋានកិច្ចការសិប្បកម្ម
- នាយកដ្ឋានផែនការ និងជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម
- និងបំពេញភារកិច្ចមួយចំនួនទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៨- ឯកឧត្តម **ទិច ស៊ីនី** អនុរដ្ឋលេខាធិការ, ជំនួយការថ្នាក់ដឹកនាំក្រសួងលើការងារ ៖
- នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន
- នាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម
- មជ្ឈមណ្ឌលផលិតភាពជាតិ
- និងបំពេញភារកិច្ចមួយចំនួនទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

៩- ឯកឧត្តម **កែ គី** អនុរដ្ឋលេខាធិការ, ជំនួយការថ្នាក់ដឹកនាំក្រសួងលើការងារ ៖
- នាយកដ្ឋានព័ត៌មាន
- នាយកដ្ឋានអភិវឌ្ឍន៍ស្តង់ដារ បណ្តុះបណ្តាល និងពិគ្រោះយោបល់
- នាយកដ្ឋានវិញ្ញាបនបត្រកម្ម
- និងបំពេញភារកិច្ចមួយចំនួនទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

១០- លោកជំទាវ **ឃុន ថាវី** អនុរដ្ឋលេខាធិការ, ជំនួយការថ្នាក់ដឹកនាំក្រសួងលើការងារ ៖
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
- និងបំពេញភារកិច្ចមួយចំនួនទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

១១- ឯកឧត្តម **សយ តីរមៀ** អនុរដ្ឋលេខាធិការ, ជំនួយការថ្នាក់ដឹកនាំក្រសួងលើការងារ ៖
- នាយកដ្ឋានទឹកស្អាត
- នាយកដ្ឋានបញ្ញត្តកម្ម
- មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា
- និងបំពេញភារកិច្ចមួយចំនួនទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

១២- ឯកឧត្តម **អ៊ុច ម៉ូរ៉ា** អនុរដ្ឋលេខាធិការ, ជំនួយការថ្នាក់ដឹកនាំក្រសួងលើការងារ ៖
- នាយកដ្ឋាននីតិកម្ម
- នាយកដ្ឋានវាយតម្លៃទទួលស្គាល់
- នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ
- នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ
- និងបំពេញភារកិច្ចមួយចំនួនទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

១៣- ឯកឧត្តម **លឹម គង់** អនុរដ្ឋលេខាធិការ, ជំនួយការថ្នាក់ដឹកនាំក្រសួងលើការងារ ៖
- នាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម
- នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ
- និងបំពេញភារកិច្ចមួយចំនួនទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

១៤- ឯកឧត្តម **មាន សុភា** អនុរដ្ឋលេខាធិការ, ជំនួយការថ្នាក់ដឹកនាំក្រសួងលើការងារ ៖

- នាយកដ្ឋានរដ្ឋបាល
- នាយកដ្ឋានកិច្ចការឧស្សាហកម្ម
- និងបំពេញភារកិច្ចមួយចំនួនទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

១៥- ឯកឧត្តម **ជួន ឆន** អនុរដ្ឋលេខាធិការ, ជំនួយការថ្នាក់ដឹកនាំក្រសួងលើការងារ ៖

- អគ្គាធិការដ្ឋាន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- ប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការិយាល័យច្រកចេញចូលតែមួយ
- និងបំពេញភារកិច្ចមួយចំនួនទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

១៦- ឯកឧត្តម **សុន សេដ្ឋា** អនុរដ្ឋលេខាធិការ, ជំនួយការថ្នាក់ដឹកនាំក្រសួងលើការងារ ៖

- នាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម
- នាយកដ្ឋានកិច្ចការសិប្បកម្ម
- នាយកដ្ឋានផែនការ និងជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម
- និងបំពេញភារកិច្ចមួយចំនួនទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

**ប្រការ២** ៖ ក្នុងករណីចាំបាច់ ឬមានកិច្ចការបន្ទាន់ចំពោះមុខ ហើយចំពេលដែលមន្ត្រី ឬថ្នាក់ដឹកនាំទទួលបន្ទុក រូបណាម្នាក់អវត្តមាន ចរន្តឯកសារដែលត្រូវលើកយោបល់ជូនរដ្ឋមន្ត្រីពិនិត្យ និងសម្រេច អាចបញ្ជូន បន្តទៅឋានានុក្រមខ្ពស់បន្ទាប់ ដោយកត់សម្គាល់អំពីមូលហេតុអវត្តមាននៅលើកំណត់បង្ហាញ។

**ប្រការ៣** ៖ ត្រូវបានធ្វើប្រតិភូកម្មហត្ថលេខាជូនឯកឧត្តម លោកជំទាវរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ក្នុងការចុះហត្ថលេខាលើឯកសារនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ចំពោះកិច្ចការដែលមានលក្ខណៈសាមញ្ញ និងប្រព្រឹត្តទៅជាធម្មតានៃដំណើរការរដ្ឋបាលប្រចាំថ្ងៃ ដោយផ្អែកតាមគោលការណ៍ដឹកនាំរបស់រដ្ឋមន្ត្រី ឬថ្នាក់ដឹកនាំក្រសួងដែលត្រូវបានប្រគល់សិទ្ធិ។

**ប្រការ៤** ៖ បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥** ៖ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល គ្រប់អង្គភាពក្រោមឱវាទក្រសួង និងសមាសភាពដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

កន្លែងទទួល ៖

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ
- អគ្គលេខាធិការរាជរដ្ឋាភិបាល

  *«ដើម្បីជូនជ្រាប»*

- ដូចប្រការ៥ *«ដើម្បីអនុវត្ត»*
- ឯកសារ-កាលប្បវត្តិ